# រឿងព្រះគោព្រះកែវ, តេជោតំដិន ឬ ពុទ្ធទំនាយ
# បរិបទខាងមនោគមបរទេស ឬ ជាអក្សរសិល្ប៍របស់ខ្មែរ ?

ខ្មែរយើងធ្លាប់ជាអាណាចក្ររុងរឿងដែលពោរពេញទៅដោយចំណុចខ្លាំងនិងចំណុចខ្សោយ។ វាជាធម្មតាទេ មនុស្សដែលថាខ្លួនឯងពូកែឬខ្លាំង តែងតែមានចំណុចខ្សោយស្ថិតនៅក្នុងខ្លួនរបស់ពួកគេ។

យុទ្ធសាស្ត្រការធ្វើសង្គ្រាម ក៏ដូចជានយោបាយឈ្នះៗរបស់គូបដិបក្ខ តែងតែរកចំណុចខ្លាំងចំណុចខ្សោយរបស់ដៃគូខ្លួន។ ខ្មែរយើងបានប្រឈមមុខនូវជុំពពកខ្មៅបក់ផាត់មកយ៉ាងខ្លាំងម្តងហើយម្តងទៀត ដែលសេចក្តីទុក្ខក្រៀមក្រំទាំងនោះកើតឡើងពីការចុះចាញ់ទាំងសង្គ្រាមកំឡាំងបាយ កំឡាំងព្យាយាម កំឡាំងសតិបញ្ញា និងកំឡាំងចិត្តសាស្ត្រមនោគមវិទ្យា។

ពេលនេះយើងល្បងពិចារណាសិក្សាទៅលើសង្គ្រាមមនោគមវិទ្យាមើល៍ តើមានកលឧបាយណាមួយដែលយើងធ្លាប់ចាញ់ ហើយនៅមានជាបន្តរហូតមកដល់បច្ចុប្បន្ននេះ? ។

នៅសម័យលង្វែក យើងធ្លាប់ចាញ់ឧបាយកលព្រះសង្ឃថៃពីរអង្គដែលអះអាងថាព្រះពុទ្ធរូបអង្គធំនៅលង្វែកជាអ្នកបណ្តាលឲ្យប្រជារាស្ត្រនិងនាម៉ឺនមន្ត្រីឈឺ និងមានរោគរាតត្បាត រួចព្រះមហាក្សត្រក៏បញ្ជាឲ្យគេយកទៅទំលាក់ចោលក្នុងទឹកទន្លេ។ នៅពេលស្តេចនរេសូរមិនអាចវាយលុកចូលទៅក្នុងក្រុងលង្វែកបាន គេក៏បានធ្វើឧបាយបាញ់ប្រាក់ដួងចូលទៅក្នុងព្រៃឫស្សី ហើយក៏ដកទ័ពថយទៅ។ ខ្មែរយើងនឹកថាសៀមលែងមកទៀត ហើយព្រោះតែភាពក្រីក្រ ក៏នាំគ្នាត្រួសកាប់ឆ្ការព្រៃឫស្សីយកប្រាក់ដួងនោះមកប្រើ រហូតដល់ទីក្រុងលង្វែកគ្មានរបងការពារ ហើយធ្លាក់ទៅក្នុងកណ្តាប់ដៃសៀមនៅទីបំផុត ។

នេះគ្រាន់តែជាឧទាហរណ៍ខ្លះ ដើម្បីឲ្យប្រជានុរាស្ត្រខ្មែរល្បងសិក្សាមើល៍អំពីរឿងនិងពាក្យពេជន៍ដូចតទៅនេះ

~ រឿងពុទ្ធទំនាយ ឥន្ទទំនាយ តើជារឿងឲ្យខ្មែរយើងកាប់បំពង់រង់ចាំទឹកភ្លៀងឬទេ?

- រឿងព្រះគោ ព្រះគោកែវ និងរឿងតេជោតំដិនជាដើម តើអាចជារឿងបង្កើតជំនឿអរូបីយ៍មហិទ្ធិឫទ្ធិក្នុងប្រយុទ្ធតស៊ូជាខ្មាំងសត្រូវឬទេ?
- ពាក្យថាបាងកករលំ ភ្នំពេញរលាយ ព្រៃនគរខ្ចាត់ខ្ចាយ សប្បាយអង្គរវត្ត តើអាចជាពាក្យពេជ្របន្ទុចបង្អាក់មិនឲ្យមានការងើបឡើងតស៊ូឬទេ?
- កូនចៅអើយ ចូរដាំដើមល្វ ធ្វើគធ្វើថ្លង់ តើអាចជាឧបាយកលមិនឲ្យខ្មែរនិយាយស្តីនិងងើបឡើងតស៊ូឬទេ?

សំណួរខាងលើនេះ គ្រាន់តែគំរុយទុកឲ្យបងប្អូនប្រជាជនខ្មែរទាំងអស់យកទៅគិតនិងពិចារណាដោយខ្លួនឯងចុះ ។